ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០១ សហវ.គររ.អគថ

# សារាចរ
# ស្តីពី
# ប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦

អនុលោមតាមមាត្រា ៥១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៣, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមដាក់ឱ្យអនុវត្តប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦ ដូចខាងក្រោម៖

ក-ដំណាក់កាលនៃការរៀបចំផែនការកម្រិតយុទ្ធសាស្ត្រ

-ចាប់ពីសប្តាហ៍ទី ១ នៃខែ កុម្ភៈ ឆ្នាំ ២០២៥ ដល់សប្តាហ៍ទី ៤ នៃខែ មីនា ឆ្នាំ ២០២៥, ក្រុមការងារជំនាញនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចាប់ផ្តើមកិច្ចដំណើរការពិគ្រោះយោបល់កម្រិតបច្ចេកទេសជាមួយក្រុមការងារជំនាញនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីប្រមូលធាតុចូលសំខាន់ៗ ដូចជា គោលនយោបាយថ្មី (New Policy) និង កត្តាជំរុញតម្រូវការ (Demand Driver) ជាដើម សម្រាប់ជាមូលដ្ឋាននៃការរៀបចំក្របខ័ណ្ឌថវិការយៈពេលមធ្យម ជាពិសេស សម្រាប់ការដាក់ចេញ **ពិតានចំណាយគោល** សម្រាប់ក្រសួង ស្ថាប័ន ឱ្យមានភាពជាក់ស្តែង និងគ្រប់ជ្រុងជ្រោយ។ នៅក្នុងកំឡុងពេលនេះដែរ ក្រុមការងារជំនាញនៃអគ្គនាយកដ្ឋានថវិកា ចាប់ផ្តើមពិភាក្សាជាជំហានៗអំពីផែនការសមិទ្ធកម្មប្រចាំឆ្នាំ នៅកម្រិតកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព សម្រាប់ការត្រៀមរៀបចំថវិកាសមិទ្ធកម្មឆ្នាំ ២០២៦។

-នៅសប្តាហ៍ទី ៤ នៃខែ មេសា ឆ្នាំ ២០២៥, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំ និងស្នើសុំការសម្រេចលើក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ ពីរាជរដ្ឋាភិបាល តាមរយៈកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។ ព្រមជាមួយគ្នានេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំ និងស្នើសុំការពិនិត្យ និងសម្រេចពី **សម្តេចធិបតីនាយករដ្ឋមន្ត្រី** លើក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ ដើម្បីដាក់ចេញពិតានចំណាយគោលសម្រាប់ឆ្នាំ ២០២៦-២០២៨ ជូនគ្រប់ក្រសួង-ស្ថាប័ន។

-នៅដើមខែ ឧសភា ឆ្នាំ ២០២៥, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំ និងស្នើសុំការពិនិត្យ និងសម្រេចពី **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ដើម្បីដាក់ចេញនូវសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៦-២០២៨ និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦។

ខ-ដំណាក់កាលនៃការរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំ

ផ្អែកតាមគោលការណ៍ណែនាំដែលត្រូវបានកំណត់ក្នុងសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៦-២០២៨ និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦, គ្រប់ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៦-២០២៨ និង គម្រោងថវិកាលម្អិតឆ្នាំ ២០២៦ ព្រមទាំងត្រូវភ្ជាប់មកជាមួយនូវផែនការសមិទ្ធកម្មប្រចាំឆ្នាំ ២០២៦ សម្រាប់ដំណើរការកិច្ចប្រជុំពិនិត្យ ពិភាក្សា និងចរចាថវិកា ដែលនឹងត្រូវធ្វើឡើងជា ២ កម្រិត ដូចខាងក្រោម៖

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

(ទី១)-កិច្ចប្រជុំកម្រិតបច្ចេកទេស៖ ការប្រជុំពិភាក្សាគម្រោងថវិការបស់គ្រប់ក្រសួង ស្ថាប័ន នឹងត្រូវធ្វើជាបន្តបន្ទាប់នៅក្នុងខែ កក្កដា ដោយចាប់ផ្តើមពីថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០២៥ និង

(ទី២)-កិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំ៖ ការប្រជុំពិភាក្សាគម្រោងថវិការបស់គ្រប់ក្រសួង ស្ថាប័ន នឹងត្រូវដំណើរការជាបន្តបន្ទាប់នៅក្នុងខែ សីហា ដោយចាប់ផ្តើមពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០២៥។

គ-ដំណាក់កាលនៃការអនុម័តសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦ នឹងត្រូវដំណើរការអនុម័តតាមប្រតិទិនដូចខាងក្រោម៖

-ក្នុងកំឡុងពាក់កណ្តាលខែ តុលា ឆ្នាំ ២០២៥, សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦ ត្រូវបានដាក់ឆ្លងក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដើម្បីធ្វើការពិនិត្យ និងសម្រេច។

-យ៉ាងយូរនៅសប្តាហ៍ទី ៤ នៃខែ តុលា ឆ្នាំ ២០២៥, សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦ និងសំណុំឯកសារពាក់ព័ន្ធផ្សេងទៀត ត្រូវបានបញ្ជូនទៅដល់រដ្ឋសភា ដើម្បីធ្វើការពិនិត្យ និងអនុម័ត។

-យ៉ាងយូរនៅសប្តាហ៍ទី ១ នៃខែ ធ្នូ ឆ្នាំ ២០២៥, សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦ និងសំណុំឯកសារពាក់ព័ន្ធផ្សេងទៀត ត្រូវបានបញ្ជូនទៅដល់ព្រឹទ្ធសភា ដើម្បីពិនិត្យ ហើយផ្តល់មតិយោបល់ មុនថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០២៥។

-យ៉ាងយូរត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៥, ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រម ព្រមទាំងបែបបទអនុវត្តច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៦ ត្រូវបានរៀបចំចប់សព្វគ្រប់។

ទទួលបានសារាចរនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្សព្វផ្សាយ អនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ សៅរ៍ ១៣ កើត ខែ ពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គនាយកដ្ឋានថវិកា
- គ្រឹះស្ថានសាធារណៈរដ្ឋបាល
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរជំនាញរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ